ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ពាមជ្រៃ

ភូមិ : ពាមជ្រៃ

ឃុំ : កោះថ្កូវ

ស្រុក : ជលគិរី

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ពាមជ្រៃ

ភូមិ : ពាមជ្រៃ

ឃុំ : កោះថ្កូវ

ស្រុក : ជលគីរី

ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **ពាមជ្រៃ** ត្រូវបានបង្កើត ឡើងដោយម ហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៣** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបាន ធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃ **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **ពាមជ្រៃ** មានទីតាំងស្ថិតនៅក្នុងភូមិ **ពាមជ្រៃ** ឃុំ **កោះថ្កូវ** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **២៣៦** នាក់ ស្រីចំនួន **១១៩** នាក់ និងមានគណៈកម្មការចំនួន **៧** នាក់ ស្រីចំនួន **១** នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **៩៨** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន :

- លក្ខន្តិកៈសហគមន៍នេសាទ និងបទបញ្ជាផ្ទៃក្នុង
- ផែនទីសហគមន៍
- កិច្ចព្រមព្រៀង
- ចុះបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- កន្លែងអភិរក្ស
- បណ្តុះកូនឈើប្រភេទព្រៃលិចទឹក
- សាងសង់រោងបុណ្យភូមិ
- សហការជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំរាល់គ្រប់សកម្មភាពរបស់សហគមន៍នេសាទ
- សហការជាមួយជំនាញជលផលទប់ស្កាត់រាល់បទល្មើសនៅក្នុងកន្លែងនេសាទសហគមន៍នេសាទ
- សហការជាមួយអង្គការ ស៊ីស៊ីឌីបង្កើតក្រុមសន្សំប្រាក់

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **៥៧២** នាក់ **១០៣** គ្រួសារ បុរស **២៦៨** នាក់ ស្រី **៣០៤** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៥៧២** នាក់ ខ្មែរឥស្លាម **គ្មាន** អាណិកជនវៀតណាម **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៦ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១០ នាក់ ស្រី ២ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៦ នាក់ ស្រី ៤ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ១៥ នាក់ ស្រី ១៣ នាក់

- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៩ នាក់ ស្រី ៥ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%** ។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **១០៩** នាក់ ស្រី **៨៩** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **១៣០** នាក់ ស្រី **៧០** នាក់ កំរិតមធ្យមសិក្សា ចំនួន **២២** នាក់ ស្រី **១០** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **១** នាក់ ស្រី **គ្មាន** ។

**៦-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ១០៣ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ១០៣ គ្រួសារ ទំហំ ១៤៧ ហិកតា
- ធ្វើវារីវប្បកម្មចំនួន ១០គ្រួសារ ទំហំ ០,៥ ហិកតា តាមស្រះចិញ្ចឹម
- ដាំបន្លែចំនួន ៩៧ គ្រួសារ ទំហំ ០,៥ ហិកតា
- ជាងផ្ទះចំនួន ៧ គ្រួសារ
- ធ្វើចំការចំនួន ៣០ គ្រួសារ ទំហំ ១៥ ហិកតា
- ធ្វើសិប្បកម្មចំនួន ៧ គ្រួសារ ( ត្បាញកន្ទេល)
- ចិញ្ចឹមសត្វ ៩៥ គ្រួសារ
- លក់ដូរ ចំនួន ១០ គ្រួសារ ( លក់ចាប់ហួយ)
- កែច្នៃផលនេសាទ ១០៣ គ្រួសារ ( ជាលក្ខណៈគ្រួសារ)
- ម៉ាស៊ីនកិនស្រូវ ១២ គ្រួសារ
- ដាំក្រចៅ ៧ គ្រួសារ
- ដាំកក់ ៤ គ្រួសារ
- ស៊ីឈ្នួលគេ ៣៥ គ្រួសារ ( កម្មករសំណង់ និងរោងចក្រ)

## ៣. តំបន់នេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងតំបន់នេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **ពាមជ្រៃ** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **១៤** និង ជាដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **ពាមជ្រៃ** មានទំហំ **៤៩៧** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ភូមិទន្លេក្រៅ**
- ខាងត្បូងទល់នឹង **ភូមិពាមពពេច**

- ខាងកើតទល់នឹង **ទន្លេ**
- ខាងលិចទល់នឹង **ភូមិភ្លូង និង ពាមពពេច**

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **ពាមជ្រៃ** មានបឹងចំនួន **២** ប្រឡាយចំនួន **៥** ត្រពាំងចំនួន **៣** ព្រៃក បៀ និង មេទឹក **គ្មាន**

- បឹងឈ្មោះ **ក្រចាប់** ទំហំ ១៦ ហិកតា នេសាទ ជាប្រចាំ
- បឹងឈ្មោះ **ភ្លូង** ទំហំ ៥ ហិកតា នេសាទ ជាប្រចាំ
- ត្រពាំងឈ្មោះ **ថាស** ទំហំ ០,៥ ហិកតានេសាទ ពីខែ កក្កដា ដល់ខែ ធ្នូ
- ត្រពាំងឈ្មោះ **កក់** ទំហំ ១ ហិកតា នេសាទ ជាប្រចាំ
- ត្រពាំងឈ្មោះ **តាដេង** ទំហំ ០,៦ ហិកតា គ្មាននេសាទ
- អាងទឹកឈ្មោះ **ក្រចាប់** ទំហំ ១០១ ហិកតា នេសាទ ជាប្រចាំ
- ស្រះមាន **១០**គ្រួសារ
- ប្រឡាយឈ្មោះ **តាជី** ទំហំ ៤ម x ៨០ម គ្មាននេសាទ
- ប្រឡាយឈ្មោះ **តាដេង** ទំហំ ៤ម x ១០០ម គ្មាននេសាទ
- ព្រៃលិចទឹក ទំហំសរុប ៦ ហិកតា
- ព្រៃឈ្មោះ **ខ្នងគោ** ទំហំ ១ ហិកតា
- ព្រៃឈ្មោះ **បឹងភ្លូង** ទំហំ ៥ ហិកតា
- ដីទំនាបលិចទឹកមាន ទំហំ **៤៩៧** ហិកតា ។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **ក្រចាប់** ទំហំ **១៦** ហិកតា

  ព្រៃឈ្មោះ **ភ្លូង** ទំហំ **៥** ហិកតា

**ឃ. ធនធានផលផល**

<u>ប្រភេទត្រី :</u>

- ប្រភេទត្រីដែលកើនឡើង: ឆ្តោរ, រ៉ស់ ក្ដី ខ្នាន់ កាប ក្រាញ់ លិញ រៀល ក្រុស ស្រកាក្ដាម ប្រា ពោ កន្ទ្រប់ កញ្ចុះ សណ្ដាយ ព្រួល ឆ្លាំង ។
- ប្រភេទត្រីដែលមិនថយ និងមិនកើនឡើង : ព្រលូង ក្រពាត់ ដៀប កន្ធនជ័យ កន្ធរ អណ្ដែង . ច្រកែង ឆ្កិន.។
- ប្រភេទត្រីដែលថយចុះ: ត្រីព្រួល

- **ប្រភេទវារីសត្វ :** អណ្ដើក កន្ធាយ ពស់ ស្វា អន្ទង់ ក្រពើ (ថយចុះ) ក្ដាម ខ្យង ខ្ចៅ កំពិស កង្កែប ហ៊ីង ស្មើន (នៅដដែល)។

**ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ :** បបុស, បបួយ ត្រសេក, ច្រកែង ថ្មើមអណ្ដើក រាំង ត្រស់ ព្រលិត ត្រកួន អញ្ចាញ ឆ្អឹងពស់ ខ្លាញ់មាន់ ស្លាបពុប ក្អែក បន្លាស្អិត ត្រដិត ដើមធ្មេញកញ្ចុះ ឃ្លេ ញញា បន្លាយូន។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន **២៣៦** នាក់ ស្រី **១៥** នាក់ **៩៨** គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន **២** នាក់ ស្រី គ្មាន
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន **៤០** នាក់ ស្រី គ្មាន។

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ:

**តារាង ១:**

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | **រដូវប្រើប្រាស់ឧបករណ៍ (ពីខែដល់ខែ)** |
|---|---|---|---|---|
| មង | ១ដៃ=៨០ម | (២ដៃ x ៧៥ម)= ១៥០ដៃ | ប្រវែងចំនួន=១២០០០ម. ជំរៅ=១.៥ម.ក្រលា=២.៥-៦សម | ខែសីហា-កុម្ភៈ |
| សៃយឺនកំពិស | គ្រឿង | (១ន x ៥០គ្រ)=៥០ | ៥០គ្រឿង | ខែតុលា-កញ្ញា |
| សន្ទូចរនង | ផ្លែ | (៣០ន x ៣០០ផ្លែ)=៩០០០ផ្លែ | ៩០០០ផ្លែ.ផ្លែលេខ=១១-១៣ | ខែកញ្ញា-តុលា |
| សន្ទូចបង្កៃ | គ្រឿង | (១៥ន x ១០ន)=១៥០ | ១៥០គ្រឿង | ខែវិច្ឆកា-ធ្នូ |
| លប | គ្រឿង | (៨ល x ១០ន)=៨០ | ៨០គ្រឿង.កំពស់=១.៥ម មុខកាត់=៦០សម.គ្រៀម=៣សម | ខែកញ្ញា-វិច្ឆិកា |
| ឡើ | គ្រឿង | (១០ន x ១០)=១០០ | ១០០គ្រឿង | ខែតុលា-ធ្នូ |

**តារាង ២:**

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកចែវ | ៣០គ្រឿង | ២០០ គក្រ | - |
| ទូកត្មោត | ២០គ្រឿង | ១០០ គក្រ | - |
| កាណូត | ៣២គ្រឿង | ២០០-៥០០គក្រ | ៣.៥សេះ- ៧ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

ចូលទាំងអស់គ្នាជាសមាជិកសហគមន៍នេសាទ

**តារាង ៣:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ពីខែដល់ខែ) |
|---|---|---|---|---|
| មង | ១ដៃ=៨០ម | (២ន x ២៥ម) = ៥០ ដ | ប្រវែងចំនួន=៤០០០ម.ក្រលា=២.៥-៦សម. ជំរៅ=១.៥ម | ខែសីហា-កុម្ភៈ |
| សន្ទូចរនង | ផ្លែ | (៣០០ផ្លែ x១០ន)=៣០០០ | ៣០០០ផ្លែ | ខែកញ្ញា-តុលា |
| សន្ទូចបង្កៃ | គ្រឿង | (២ន x ១០ន)=២០ | ២០គ្រឿង | ខែកញ្ញា-តុលា |

**តារាង ៤:**

| ប្រភេទទូក -កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៣គ្រឿង | ២០០ គក្រ | - |
| ទូកត្នោត | ៤គ្រឿង | ១០០ គក្រ | - |
| កាណូត | ២គ្រឿង | ២០០-៥០០គក្រ | ៥សេះ - ៧.៥ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

**តារាង ៥:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ពីខែដល់ខែ) |
|---|---|---|---|---|
| សន្ទូចរនង | ផ្លែ | (៥ន x ២០០ផ្លែ)=១០០០ផ្លែ | ចំនួន=១០០០ផ្លែ.លេខ=១១ | ខែមីនា-មេសា |

**តារាង ៦:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ១០ | ១០០ | - |
| ទូកត្នោត | ២០ | ៥០ | - |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

**តារាង ៧:**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ១២៥០ គក្រ | ១៨០០គក្រ | ៣០៥០ គក្រ |
| ក្តាម ខ្យង | ២៥០ គក្រ | ៣០០ គក្រ | ៥៥០គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **ពាមជ្រៃ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

<u>តារាង ៨:</u>

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងក្រចាប់ | ពីខែមករា-ធ្នូ | មង | ៤.៨០០ម | ៤០នាក់ | ក្រឡាពី២,៥ស.ម-៩ស.ម |
| | ពីខែកក្កដា-មករា | សន្ទូចរនង | ៦.០០០ថ្លៃ | ២០នាក់ | - |
| | ពីខែមករា-មិថុនា | លប | ១៥០លប | ៣០នាក់ | ៨០គ្រឿង.កំពស់=១.៥ម មុខកាត់=៦០សម.ត្រៀម=៣សម |
| | ពីខែកុម្ភៈ-មិថុនា | សំណាញ់ | ១០វង់ | ១០នាក់ | ក្រឡាពី៣ស.ម-៥ស.ម |
| បឹងភ្លូង | ពីខែមេសា-មិថុនា | អង្រុត | ២៥អង្រុត | ២៥នាក់ | - |
| | ពីខែធ្នូ-ឧសភា | មង | ១.២០០ម | ១៥នាក់ | ក្រឡាពី២,៥ស.ម-៩ស.ម |
| | ពីខែកុម្ភៈ-មិថុនា | សំណាញ់ | ៥វង់ | ៥នាក់ | ក្រឡាពី៣ស.ម-៥ស.ម |
| | ពីខែកុម្ភៈ-ឧសភា | បង្កៃ | ២៥០ ថ្លៃ | ៥នាក់ | - |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

តារាង ៩:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ទំនប់ក្រចាប់ | ១.២១៥ម | ១៥មx៥មx៣.៥ម | ជួសជុល | ខែឧសភា ២០០៩ | ខែមិថុនា ២០០៩ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

តារាង ១០:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងក្រចាប់ | ៣ ហិចតា | ត្រីមេពូជ | ព័ទ្ធបន្ទាលួស | ឧសភា ២០០៩ | ឧសភា ២០០៩ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

តារាង ១១:

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងភ្លង | ៥.៨២ហិចតា | ដើមរាំង | -កំណត់ព្រំប្រទល់<br>-ផ្សព្វផ្សាយ<br>-បណ្តុះ ដាំ<br>-ដាកស្លាកសញ្ញា<br>-ការពារ ថែរក្សា | ខែមករា ២០០៩ | ខែឧសភា ២០០៩ | |
| បឹងភ្លង | ១.៥៣ហិចតា | ដើមរាំង | -កំណត់ព្រំប្រទល់<br>-ផ្សព្វផ្សាយ<br>-បណ្តុះ ដាំ<br>-ដាក់ស្លាកសញ្ញា | ខែមករា ២០០៩ | វិច្ឆិកា ២០០៩ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | -ការពារ ថែរក្សា | | | |
| ខ្លងគោ | ១ ហិកតា | ប្រភេទព្រៃចំរុះ | -កំណត់ព្រំប្រទល់<br>-ផ្សព្វផ្សាយ<br>-ដាក់ស្លាកសញ្ញា<br>-ថែរក្សា ការពារ | មករា ២០០៩ | ខែធ្នូរ ២០១០ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម៖

**តារាង.១២:**

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើមចិញ្ចឹម | ប្រមូលផល |
| ស្រះបេ=៨ម.ទ=៤ម | ០៨ស្រះ | ត្រីឆ្ពិន | ចំនួន=១៦០០០ក្បាល<br>១ស្រះ=២០០០ក្បាល | ខែវិច្ឆកា ២០០៩ | ខែសីហា ២០១០ |
| ស្រះបេ=៨ម.ទ=៦ម | ០៨ស្រះ | ត្រីប្រា | ចំនួន=១៤៤០០ក្បាល<br>១ស្រះ=១៨០០ក្បាល | ខែមេសា ២០០៩ | ខែមិថុនា២០១០ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

**តារាង ១៣:**

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលថវិកា | ខែឧសភា ២០០៩ | ខែឧសភា ២០១០ | ១១៨.០០០ | រៀល |
| ភាគទានប្រចាំឆ្នាំ | ប្រមូលថវិកា | ខែឧសភា ២០០៩ | ខែឧសភា ២០១០ | ៣៥៤.០០០ | រៀល |
| ភាគទានអ្នកទេសចរមកពីក្រៅតំបន់ | ប្រមូលថវិកា | ខែមីនា ២០០៩ | ខែមិថុនា ២០១០ | ៧២.០០០ | រៀល |

## គ-៧ ផែនការសុខភាព និងអនាម័យ

**តារាង ១៤:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| បណ្តុះបណ្តាលការចិញ្ចឹមសត្វ និងព្យាបាលសត្វ | ៦០ | ៦០នាក់ | ១០០ដុល្លារ | ខែឧសភា ២០០៩ | ខែកញ្ញា ២០០៩ |

| | | | |
|---|---|---|---|
| | ផ្សាយ និងប្រគល់ឱ្យសមាជិកសហគមន៍ក្រីក្រផ្សេង ចិញ្ចឹមមាន់បន្ត | | |
| ៥០គ្រួសារ | ប្រជុំរៀបចំក្រុមបណ្តុះផ្សិតអំបោះដែលជាសមាជិកមាន ជីវភាពក្រីក្របណ្តុះបណ្តាលបច្ចេកទេសនិងឯកសារ ផ្តល់ប្រាក់កម្ចីដើម្បីជាដើមទុនក្នុងការបណ្តុះផ្សិតអំបោះ និងធ្វើរោងផ្សិតឱ្យសមាជិក ស.ន .តាមដាន និងវាយ តម្លៃសកម្មភាពដែលបានអនុវត្ត .ប្រមូលប្រាក់ដើមពី សមាជិកសហគមន៍ដែលបានខ្ចី មក បណ្តុះផ្សិត.ប្រជុំ ផ្សព្វផ្សាយ និងប្រគល់ឱ្យសមាជិកសហគមន៍ក្រីក្រ ផ្សេងៗទៀតបន្ត | | |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះ ដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង នឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹកកន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមថ្ងៃ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

**តារាង ១៧:**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១-ការប្រើប្រាស់ឧបករណ៍នេសាទ | ត្រួតពិនិត្យតាមបឹងក្រចាប់ និងបឹងភ្លូង | ជំរុញឱ្យសមាជិកស.នប្រើប្រាស់ឧបករណ៍នេសាទតាមផែនការដែលបានកំណត់បឹងនីមួយៗ | ៨០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមករា-កក្កដា ២០០៩ | ខែមករា-កក្កដា ២០១០ | |
| ២. ការកែលំអដែននេសាទ | ជួសជុលទំនប់ក្រចាប់ប្រវែង ១.២១៥ម (១៥មx៥មx៣.៥ម) | អាងទឹកបឹងក្រចាប់នឹងមានទឹកជ្រៅនៅរដូវប្រាំងសម្រាប់រក្សាផលស្តុកត្រី និងមានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែប្រាំង | ២០០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែឧសភា ២០០៩ | ខែមីថុនា ២០០៩ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | ព័ទ្ធបន្ទាលួសឡើងវិញនៅតំបន់អភិរក្សបឹងក្រចាប់ | តំបន់អភិរក្សនឹងធានាការពារបានកាន់តែប្រសើរឡើងដែលមានទំហំ៣ហិកតា | ១៥០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែឧសភា ២០០៩ | ខែឧសភា ២០០៩ | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | បោះស្លាកសញ្ញា បោះបង្គោល និង ផ្សព្វផ្សាយ បណ្ដុះកូនឈើដាំ និងផ្សព្វផ្សាយ ល្បាត និងបោះស្លាកសញ្ញា | ទំហំព្រៃលិចទឹកចំនួន ២៥.៧១ហិកតាការពារទុកជាជំរក សម្រាប់ជីវចំរុះគ្រប់ប្រភេទ | ១២០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់រដ្ឋាភិបាល | ខែមករា ២០០៩ | ខែធ្នូ ២០១០ | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ផ្ដល់កូនត្រីពូជដល់សមាជិកសហគមន៍នេសាទ | សមាជិកសហគមន៍នេសាទនឹងទទួលបានកូនត្រីចំនួន | ៧០០ ដុល្លា | -អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងផ្សេងៗរបស់ | វិច្ឆកា២០០៩ | ខែសីហា ២០០៩ | កូនត្រីប្រា និង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ២២.៥០០ កូនដាក់ក្នុងស្រះ ចំនួន ១៥ | | រដ្ឋាភិបាល | | | ឆ្អិន |
| ៦. ផែនការថវិកាទ្រទ្រង់អភិវឌ្ឍន សហគមន៍ | ប្រមូលប្រាក់ភាគទានពីសមា-ជិកសហគមន៍នេសាទប្រាក់ភាគទានប្រចាំឆ្នាំនិងប្រាក់ភាគទានអ្នកនេសាទមកពីក្រៅ | សមាជិកសហគមន៍នេសាទ និងបង់ប្រាក់គ្រប់ចំនួន | ២០០ ដុល្លា | -គណៈកម្មការសហគមន៍នេសាទ | ខែឧសភា ២០០៩ | ខែមីថុនា ២០១០ | |
| ៧. ផែនការសុខភាព និង អនាម័យ | ផ្តល់បង្គន់អនាម័យ ធុងចម្រោះទឹកស្អាត និងវគ្គបណ្តុះបណ្តាល | កាត់បន្ថយភាពកខ្វក់ និងជំងឺឆ្លងនៅក្នុងភូមិ និងយល់ដឹងពីបច្ចេកទេសចិញ្ចឹម និងព្យាបាលសត្វដល់សមាជិកសហគមន៍នេសាទចំនួន ១០០គ្រួសារ | ១៩០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែមករា ២០០៩ | ខែសីហា ២០០៩ | |
| ៨. ផែនការកសាងក្នុងស.ន | សង់ស្នាក់ការសហគមន៍ ទិញកាណូត និងធ្វើជង្រុកស្រូវ | ស.ន នឹងមានទីកន្លែងសម្រាប់ប្រជុំពិភាក្សា មានកាណូតសំ រាប់ចុះធ្វើការងារផ្សេងនៅក្នុង សហគមន៍ និងជង្រុក ធនាគារស្រូវ | ៥៧០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែមីថុនា ២០០៩ | ខែកក្កដា ២០១០ | |
| ៩. ផែនការទ្រទ្រង់ជីវភាពសមាជិកស.ន | ចិញ្ចឹមមាន់ ទា ជ្រូក គោ និងក្របី និងគ្រប់ពូជបន្លែ | សមាជិកសហគមន៍ចំនួន ១១០ គ្រួសារនឹងអាចរកចំណូលបន្ថែមតាមរយៈការចិញ្ចឹមសត្វ | ៤០៣០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមករា ២០០៩ | ខែធ្នូ ២០១០ | |

| សកម្មភាព | តារាងកម្មវិធីការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៧. ផែនការសុខភាព និងអនាម័យ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | |
| ៨. ផែនការកសាងក្នុងសហគមន៍នេសាទ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ៩. ផែនការទ្រទ្រង់សមាជិកសហគមន៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

បានឃើញ និងបញ្ជូនមក

លោកនាយ...រដ្ឋបាលជលផល.......

**នាយសង្កាត់រដ្ឋបាលជលផល**...

.......ថ្ងៃទី...17.......ខែ...10.....ឆ្នាំ ២០08

លេខ :.............

**បានឃើញ**

**មេឃុំ**........

.......ថ្ងៃទី...17.....ខែ...10.....ឆ្នាំ ២០០8

លេខ :...408 ...

.......ថ្ងៃទី...17.......ខែ....10......ឆ្នាំ ២០08

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :...02...

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ.........ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"

.......ថ្ងៃទី...27...ខែ.....11...ឆ្នាំ ២០០ 8

**នាយអធិការដ្ឋាន...រដ្ឋបាលជលផល**...

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន...រដ្ឋបាលជលផល...

.......ថ្ងៃទី...21...ខែ.....10....ឆ្នាំ ២០០ 8

**នាយខណ្ឌរដ្ឋបាលជលផល**......